Washington State
Department of Social & Health Services
CA Children's Administration

# (សូមអានទំព័រនេះមុននឹងបំពេញក្រដាសពាក្យសុំ)
# និតិវិធីដាក់ពាក្យសុំសំរាប់កម្មវិធីឧបត្ថម្ភការ
# សុំក្មេងមកចិញ្ចឹម និង/ឬការចេញប្រាក់សងវិញ
# នៃតំលៃនៃការបញ្ចប់ការសុំក្មេងមកចិញ្ចឹម

PROCEDURES FOR APPLYING TO THE ADOPTION SUPPORT PROGRAM
AND/OR REIMBURSEMENT OF ADOPTION FINALIZATION COSTS

ពត៌មានដូចខាងក្រោមនេះនឹងជួយអ្នកក្នុងការបំពេញក្រដាសពាក្យសុំដែលភ្ជាប់មកជាមួយនេះ ដើម្បីដាក់ពាក្យសុំសំរាប់កម្មវិធីការឧបត្ថម្ភសុំក្មេងមកចិញ្ចឹម ហើយនិងការដាក់ពាក្យសំរាប់ចេញប្រាក់សងវិញនៃតំលៃនៃការបញ្ចប់ការសុំក្មេងមកចិញ្ចឹមរបស់អ្នក ។ សូមបំពេញក្រដាសពាក្យសុំមួយសន្លឹកសំរាប់ក្មេងម្នាក់ ។ ក្រដាសពាក្យសុំនឹងត្រូវពិនិត្យឡើងវិញដោយនាយកគ្រប់គ្រងផ្នែកកម្មវិធីការឧបត្ថម្ភសុំក្មេងមកចិញ្ចឹម ។ ចូរគូសប្រអប់នៅក្នុងក្រដាសពាក្យសុំដើម្បីបញ្ជាក់ថា អ្នកបានអានក្រដាសពាក្យសុំនេះ ។

## ជំពូកទី I: ក្រដាសពាក្យសុំសំរាប់កម្មវិធីការឧបត្ថម្ភសុំក្មេងមកចិញ្ចឹម

**ចូរសរសេរចុះពត៌មានដូចខាងក្រោមនេះ:**

- ឈ្មោះនាមត្រកូល នាមខ្លួន និងនាមកណ្តាលរបស់ក្មេងដែលត្រូវសុំមកចិញ្ចឹម និងឈ្មោះក្មេងសុំមកចិញ្ចឹមបានគ្រោងទុក ។
- ខែថ្ងៃកំណើតរបស់ក្មេង ។
- ឈ្មោះ ខែថ្ងៃកំណើត ពូជសាសន៍ នឹងមុខងាររបច្ចុប្បន្នរបស់អ្នក ។
- អាសយដ្ឋាន ក្រុង រដ្ឋ ស៊ីបខូដ លេខទូរស័ព្ទផ្ទះរបស់អ្នក និងលេខទូរស័ព្ទផ្សេងទៀតសំរាប់ទាក់ទងអ្នក ។

## ជំពូកទី II: ក្រដាសពាក្យសុំសំរាប់ចេញប្រាក់សងវិញនៃតំលៃនៃការបញ្ចប់ការសុំក្មេងមកចិញ្ចឹម

(ចូរបំពេញជំពូកនេះ បើសិនជាអ្នកស្នើសុំឲ្យសងប្រាក់វិញក្នុងតំលៃដែលមាននៅចុងបញ្ចប់នៃការសុំក្មេងមកចិញ្ចឹម) ។ តំលៃទាំងនេះអាចជាតំលៃប៉ាន់ប្រមាណ ។
**ចំនួនប្រាក់សងមកវិញជាអតិបរិមាគឺ $1,500.00 ។**

**A. ថ្លៃឈ្នួលផ្នែកច្បាប់** គឺជាថ្លៃឈ្នួលដែលអ្នកបង់ទៅឲ្យមេធាវីសំរាប់ការបំរើ ឈ្នួលដាក់ពាក្យប្តឹងសុំទៅតុលាការ ឈ្នួលថតចម្លង និងឈ្នួលធ្វើសំបុត្រកំណើត ។

**B. ថ្លៃឈ្នួលការដឹកនាំ** គឺជាប្រាក់ចំណាយដែលអ្នកបានធ្វើដំណើរទៅសួរសុខទុក្ខក្មេងមុនពេលយកមកចិញ្ចឹមនៅផ្ទះរបស់អ្នក ។ ការសងប្រាក់មកវិញ គឺមានតំលៃដូចនឹងអត្រាជាបុគ្គលិករបស់រដ្ឋ ។

**C. ថ្លៃឈ្នួលផ្នែកពេទ្យ** សំរាប់របាយការណ៍ការពិនិត្យរាងកាយពីគ្រូពេទ្យរបស់អ្នក និង/ឬការពិនិត្យផ្នែកពេទ្យសំរាប់ក្មេងរបស់អ្នកដែលត្រូវសុំមកចិញ្ចឹម ។

**D. ថ្លៃឈ្នួលសំរាប់ទីភ្នាក់ងារផ្នែកការសុំក្មេងមកចិញ្ចឹម** គឺជាឈ្នួលដែលអ្នកបង់ទៅទីភ្នាក់ងារឯកជន ។

**ក្រោយពេលដែលការសុំក្មេងបានបញ្ចប់អស់ហើយ** ថ្លៃឈ្នួលរបស់អ្នកដែលបានអនុញ្ញាតនឹងត្រូវសងមកឲ្យវិញ នៅពេលដែលយើងបានទទួលពត៌មាន ដូចខាងក្រោមនេះ :

- ក្រដាសចម្លងការអនុលោមតាមនៃក្រិត្យការសុំក្មេងមកចិញ្ចឹម
- ក្រដាសចម្លងនៃវិកយប័ត្រដែលបង្ហាញថាអ្នកបានបង់សំរាប់សេវានានា ដែលអ្នកបានចុះនៅក្នុងក្រដាសពាក្យសុំ
- បង្កាន់ដៃដែលមានសុពលភាពសំរាប់បង់ថ្លៃសេវានានា, ឬ
- ក្រដាសចម្លងនៃសែកដែលបានបដិសេធ

ការសងប្រាក់មកឲ្យវិញនឹងត្រូវបង់ទៅឲ្យគ្រួសារជាសែកនៅក្នុងរយ:ពេល 30 ថ្ងៃ នៃថ្ងៃដែលបានទទួលករណីរឿងនានានៅខាងលើ ។

## ជំពូកទី III: សេវាដែលបានស្នើសុំ

សូមគូសយកប្រអប់ទាំងឡាយ ដើម្បីបញ្ជាក់ពីសេវាដែលអ្នកបានស្នើសុំដើម្បីជួយក្មេងដែលអ្នកសុំមកចិញ្ចឹម ហើយនិងថា អ្នកយល់នូវការត្រូវនៃសេវាទាំងអស់នោះ ។ សូមចុះហត្ថលេខានឹងចុះខែថ្ងៃនៅក្នុងក្រដាសពាក្យសុំ ។